- តាំងពីឆ្នាំ ១៩៧៥ មកគ្នាព្រាត់ឪពុកម្ដាយបងប្អូនរហូត .. ពុំដែលបានជួបមុខគាត់សោះ . . . រហូតឆ្នាំ ១៩៧៩ វៀតណាមរំដោះ ... ក៏គ្នាពុំបានទៅដល់ផ្ទះដែរ កាលនោះគ្នានៅកងចល័ត ពេលវៀតណាមរំដោះភ្លាម ពួកគេជម្លៀសកៀរពួកគ្នាមកភ្នំនេះហើយគេឱ្យទទួលមុខនាទីខាងពេទ្យទៅ គ្នារកពេលដកឃ្លាដើម្បីទៅរកឪពុកម្ដាយពុំរួច សូម្បីតែដំណឹងក៏គ្នាពុំដែលបានទទួលដែរ ។

ភ្លាមនោះ ! ស្នូរជើងមនុស្សដើរចូលមក ។ កុសលឱ្យសញ្ញាទៅអាស្នាឱ្យឈប់និយាយ ។

- ម៉េចទៅពេទ្យ . . . វាមាននិយាយថាម៉េចទេ ?

- បាទបង ! . . . មិត្តសេននេះជាបងប្អូនបង្កើតនឹងខ្ញុំបាទ ! . . គេមិនមែនធ្វើទាហានរហូតសំរិទ្ធដូចពាក្យគេចោទប្រកាន់ទេ តាំងពីក្មេងៗមកម្ល៉េះគាត់គ្មាននិស្ស័យរឿងទាហានអីទេ ! ខ្មោចឪពុកខ្ញុំ គាត់បង្ខាត់បង្រៀនតែធ្វើស្រែប៉ុណ្ណោះទេ . . . បងខ្ញុំនេះមិនចេះអក្សរទេ គាត់នៅវត្តពីរវស្សាក៏គ្មានចេះស្អីដែរ . . . គាត់ស្លូតណាស់ ! គាត់ខ្លាចគេចាប់ធ្វើទាហាន ទើបរត់តែពិសតែពាសមកជួបកងទ័ពជាតិយើង ក៏នាំគាត់មកដល់ទីនេះ ! . . ខ្ញុំសូមធានាទាំងស្រុងចំពោះបងប្រុសខ្ញុំមួយនេះ ! . . .

សូមបងប្រធានមេត្តាដោះលែងគាត់ឱ្យមានសេរីភាពវិញទៅ ព្រោះនៅទីនេះខ្ញុំមានបងប្អូនតែពីរនាក់ទេ !

កុសលសម្លឹងមុខប្រធានស្ទាបស្ទង់ចិត្ត



- អូ ! មិត្តសេននេះត្រូវជាបងបង្កើតរបស់កុសលឯងឬ ?

- បាទបង !

ប្រធានកងមើលមុខអាស្នារួចមើលមុខកុសល

- យី ! មុខមាត់សាច់ឈាមប្រហាក់ប្រហែលមែន ! .. អញ្ចឹងកុសលឯងមើលនាំទៅព្យាបាលឲ្យផង ហើយធ្វើការជាមួយមិត្តឯងចុះណា៎ !

- បាទបង ! . . .

- កុំធ្វើអ្វីផ្ដេសផ្ដាសណា៎ប្រយ័ត្នមានគ្រោះថ្នាក់ ខ្ញុំមិនដឹងទេ ! . .

- ប្រធានកងចេញបាត់ទៅ . . . អាស្នានិងកុសលដេកលង់លក់ជាមួយគ្នាទាល់ភ្លឺទៅ ។

ជារៀងរាល់ថ្ងៃនិងរាល់យប់ កុសលតែងមកសម្រាកលេងជាមួយអាស្នាអស់រយៈពេលពីរយប់ហើយ ។ កុសលបានប្រាប់អាស្នាថាគ្នាមិនឱ្យឯងទៅសម្រាកនៅមន្ទីរពេទ្យទេ ខ្លាចឆ្លងជំងឺគ្រុនចាញ់ ព្រោះកន្លែងនោះស្មោកគ្រោកណាស់ ! ទើបគេឱ្យអាស្នាសម្រាកនៅរោងក្បែរទីឃុំឃាំងនេះ ។

ឥឡូវនេះអាស្នាបានធូរស្រាលហើយ មានកម្លាំងដូចប្រក្រតីហើយ ! .. ល្ងាចនេះកុសលបានមកបបួលអាស្នាទៅអង្គុយលេងក្បែរមាត់ជ្រោះមួយដែលមានដើមឈើត្រសុំត្រសាយ និងទឹកថ្លាយង់ . . . ។

- អង្គុយមកសម្លាញ់ ! . . នៅទីនេះស្អាតល្អណាស់ ! ហើយទេសភាពល្អស្រស់គួរឲ្យចាប់អារម្មណ៍ណាស់ !

- មែនហើយកុសល ! ធម្មជាតិនៅស្រុកខ្មែរយើងល្អត្រកាលណាស់ មិនចាញ់បរទេសប៉ុន្មានទេ !

កុសលបែរខ្លួនអង្គុយលើផ្ទាំងថ្មមួយជុំក្បែរអាស្នាទាំងវាចាមួយ ៗ ទៅកាន់អាស្នា ៖

- អាស្នា ! នៅទីនេះតើមិត្តសប្បាយទេ ?

អាស្នាងាកមើលមុខកុសលរួចញញឹម ។ ឆ្លើយតប :

- មែនហើយ ! អាស្នា ! គ្នាអាចកាត់យល់ដល់ជម្រៅចិត្តឯងហើយ ! . . . នៅទីនេះគ្មានអ្វីអាចទាក់ទាញអារម្មណ៍ឯងឲ្យសប្បាយទេ កុំតែបញ្ហាប្អូនប្រុសឯង ម៉្លេះសមឯងមិនមកកាន់ទីនេះទេ មែនទេ ? . . .

- សម្លាញ់និយាយនេះត្រឹមត្រូវណាស់ ! . . . ( អាស្នាពោលទាំងធ្វើមុខស្មើ )

- អញ្ចឹងមានន័យថា នៅឯខាងក្នុងឯណោះសប្បាយណាស់មែនទេអាស្នា ! . . .

អាស្នាងក់ក្បាលផ្ងក់ ៗ វាចាទាំងញញឹមដាក់កុសល :

- នៅឯខាងក្នុងឥឡូវខុសប្លែកដូចមេឃនិងដីពីសម័យប៉ុលពត ប្រជាជន មានសិទ្ធិសេរីភាពបរិបូណ៌ មានស្បៀង មានពាក់ហូបចុកគ្រប់គ្រាន់ ហើយសមិទ្ធផលនានាសុទ្ធតែជារបស់សមូហភាពគ្មានរបស់នាយទុនទេ ! សព្វថ្ងៃនេះ បក្សយើងបានពង្រីកយ៉ាងខ្លាំងក្លាវិស័យសេដ្ឋកិច្ច ធ្វើឲ្យជីវភាពប្រជាជនយើងបានកាន់តែធូរធារម្តងមួយកម្រិតធំថែមទៀត ។



ពិសេសជាងនេះទៅទៀតវិស័យអប់រំសិក្សាធិការ បានផុសផុលគ្រឹកគ្រេងជាងសម័យ លន់ នល់ កាលយើងនៅរៀនទៅទៀតណា !

កុសលងាកមើលមុខអាស្នាដោយរីករាយ ព្រោះចំណុចដែលគេចង់ ។ អាស្នាបន្តផ្នែកប្រពៃណី ប្រជាជនមានសិទ្ធិគ្រប់គ្រាន់ក្នុងការកាន់សាសនានិងធ្វើបុណ្យទានបានតាមប្រពៃណីជាតិ ។

កុសលដកដង្ហើមធំលោកដី :

- ហ៊ឺ ! សម្លាញ់ ! គ្នាចង់ឃើញចង់ដឹងណាស់ ! . . . ក៏ប៉ុន្តែហួសពេលហើយ !

អាស្នាងាកមករកកុសលភ្លាម :

- មិនទាន់ហួសពេលទេសម្លាញ់ ! . . . បក្សយើងសព្វថ្ងៃកំពុងអំពាវនាវឲ្យបងប្អូនដែលវង្វេងផ្លូវតាមខ្មាំងឲ្យវិលត្រឡប់ទៅរួមរស់ជាមួយបដិវត្តន៍វិញ !

កុសលគ្រវីក្បាល :

- គ្នានៅតែមិនជឿ ! . . ព្រោះគ្នាឮពួកគេដែលចុះទៅធ្វើវិច្ឆេទកម្មនៅតាមមូលដ្ឋាននិយាយថា ពួកដែលរត់ចូលទៅសុទ្ធតែត្រូវវៀតណាមអារកសម្លាប់ទាំងរស់ ។

អាស្នាសើចសំណើច ឃឹក ៗ

- សម្លាញ់យល់ខុសហើយ ! សម្លាញ់ចាញ់ឃោសនាពួកវាហើយ ! តាមការពិត បក្សយើងមានគោលមាគ៌ា ៦ ខ សន្តោសប្រោ

ប្រណីដាច់ខាតដល់ជនវង្វេងផ្លូវ ។

- បើអ្នកណាវិលទៅរួមរស់ជាមួយបដិវត្តន៍វិញ ត្រូវបានបក្ស និងប្រជាជនជួយឧបត្ថម្ភ និងទទួលស្គាល់ជាប្រជាជនធម្មតា . . .

- បើមានមុខជំនាញបច្ចេកទេសត្រូវបានបំពេញតាមសំណូមពរ

- មានសិទ្ធិសេរីភាពដូចប្រជាជនពេញសិទ្ធិ អាចត្រឡប់ទៅរួមរស់ជាមួយក្រុមគ្រួសារវិញ ឬក៏ត្រឡប់ទៅស្រុកកំណើត ។ ជាងនេះទៀត បើបុគ្គលណាមានស្នាដៃល្អក្នុងការកសាងនិងការពារប្រទេស ត្រូវបានលើកទឹកចិត្តជារង្វាន់ផ្សេងសមតាមអំពើប្រព្រឹត្តរបស់បុគ្គលនោះ ។

- បើបានអាវុធទៅផងត្រូវឲ្យជាលុយកាក់គិតតាមធុនកាំភ្លើង ! ។

កុសលអង្គុយស្តាប់អាស្នារៀបរាប់ដោយយកចិត្តទុកដាក់

- មែនឬអាស្នា ?

- ពិតប្រាកដណាស់កុសល ! បើមិត្តពុំជឿខ្ញុំហ៊ានប្រគល់ជីវិតជូនមិត្តទាំងអស់ បើចជឿហើយឬនៅ ?

កុសល . . . លូកដៃចាប់ដៃអាស្នាយ៉ាងណែន

- អាស្នាសម្លាញ់ ! បើរឿងនោះពិតមែន ! យើងនឹងរកមធ្យោបាយរត់ចេញពីទីនេះឲ្យបាន (ញញឹមបន្តិចទើបបន្ត) បើបានសម្រេចមែនប៉ុះសមខ្ញុំបានជួបឪពុកម្តាយក្រុមគ្រួសារខ្ញុំហើយ . . . ខ្ញុំមិនដឹងសប្បាយចិត្តយ៉ាងណាទេ . . .

- រឿងដែលខ្ញុំនិយាយទាំងប៉ុន្មានគឺសុទ្ធតែជាការពិតទាំងអស់ ស្ម



សម្លាញ់ទុកចិត្តចុះ ។

អាស្នានិយាយយ៉ាងម៉ឺងម៉ាត់រួចងាកមើលឆ្វេងស្តាំបន្តិចទើបបន្ត :

ខ្ញុំគិតថាយើងឃោសនាជាបណ្តើរៗ ចាំពេលដែលខ្ញុំរកប្អូនប្រុសខ្ញុំឃើញ រឿងនេះយើងធ្វើយ៉ាងស្ងាត់កុំឲ្យពួកវាដឹងខ្សឹបសោះ . . . ។

- ត្រូវហើយសម្លាញ់ . . . ខ្ញុំសន្យាថានឹងជួយរិះរកមធ្យោបាយគ្រប់បែបយ៉ាងដើម្បីទាក់ទាញបងប្អូនមួយចំនួនឲ្យត្រឡប់ទៅជាមួយយើងក្នុងពេលឆាប់ៗនេះ ។

និយាយចប់កុសល ក្រោកពត់ខ្លួន ងាកមើលនេះនោះបន្តិចទើបពោលឡើងថា :

- អូ ! . . . និយាយអញ្ចឹង ពីល្ងាចម្សិលមិញខ្ញុំបានរើសរូបថតមួយសន្លឹកក្បែរមាត់អណ្តូង ។

និយាយបណ្តើរលូកយករូបថតក្នុងហោប៉ៅអាវបណ្តើរ មកបង្ហាញអាស្នា ។

- រូបថតនេះបើខ្ញុំមិនច្រឡំទេគឺប្រាកដជារូបថតរបស់សុន្ទរីមែនទេ ...

អាស្នាភ្ញាក់ព្រើតលូករករូបថតក្នុងហោប៉ៅអាវមិនឃើញ ក៏ពោលទាំងភ្ញាក់ផ្អើលថា ៖

- សម្លាញ់រើសបានរូបថតឬ ?

- ត្រូវហើយ តើរូបថតនេះជារូបថតអ្នកណា ?

អាស្នាងក់ក្បាលមួយៗរួចឆ្លើយ ៖

- រូបថតនោះគឺរូបថតរបស់សុន្ទរីមែនហើយសម្លាញ់ គ្នាភ្លេចនៅឯមាត់អណ្ដូងពីម្សិលមិញ កុំតែបានសម្លាញ់រើសកុំអីបាត់ទៅហើយ

កុសលអង្គុយក្បែរអាស្នារួចហុចរូបថតទៅឱ្យអាស្នា ទាំងពោលពាក្យថា :

- តើឥឡូវនាងនៅឯណា អាស្នា ?

អាស្នាដកដង្ហើមធំគ្រវីក្បាលមួយៗ មិនចេញស្ដីមួយម៉ាត់ កុសលនិយាយបន្ត :

- អាស្នា ! .. សុន្ទរីកាលពីដើមស្អាតណាស់ក្នុងចំណោមមិត្តនារីរួមថ្នាក់ទាំងអស់ ... ហើយមិនត្រឹមតែមានរូបសម្បត្តិស្អាតប៉ុណ្ណោះទេ.. . នាងចិត្តល្អណាស់ ចំពោះមិត្តភក្តិប្រុសស្រី . . . អ្នកណាក៏ចូលចិត្តនាងដែរ ។ (កុសលភាម៉ឺងមុខអាស្នាដែលកំពុងលើងលោងទឹកភ្នែករួចបន្ត) អាស្នា ! តើឯងមានទឹកឃើញទេកាលដែលនាងឱ្យលុយឯងបង់ថ្លៃសាលា ឱ្យសៀវភៅសរសេរ ?

- កាលនោះនាងស្រឡាញ់ឯងណាស់ ! .. មែនទេ ? ... ចុះឥឡូវឯងបានជួបនាងហើយឬនៅ ?

អាស្នាយំខ្សឹកខ្សួល ធ្វើឱ្យកុសលមន្ទិលយ៉ាងខ្លាំង ក៏សួរដេញដោល

- តើរាយ៉ាងម៉េច ... សម្លាញ់បានជាឯងយំ ? សុន្ទរីយ៉ាងម៉េចឬ ? ..

អាស្នានិយាយទាំងអណ្ដើតអណ្ដក :



- កុសល សម្លាញ់ ... សុន្ទរីបានស្លាប់បាត់ ... ទៅហើយ !

- យី ... សុន្ទរីស្លាប់ ? មូលហេតុអីអាស្នា ?

អាស្នាក៏រៀបរាប់រឿងសុន្ទរីតាំងពីដើមរហូតដល់ចប់ធ្វើឱ្យកុសលនឹកអាណិតសុន្ទរីពេកក្រៃ ... ។ (កុសលដកដង្ហើមធំគ្រវីក្បាលទាំងសោកស្ដាយសុន្ទរី )

- ហ៊ឺ ! អាស្នាសម្លាញ់ ! ... កាលឆ្នាំ ១៩៧៥ សុន្ទរីជម្លៀសមកនៅភូមិជាមួយនឹងខ្ញុំ ពេលបានចំណីអាហារបន្តិចបន្តួចនាងមិនដែលហូបចុកតែឯងទេ នាងតែងចែករំលែកមកខ្ញុំខ្លះជានិច្ច ! .. .ហើយនាងតែងតែពោលរំលឹកពីឈ្មោះឯងជានិច្ចសម្លាញ់ ... រូបថតរបស់ឯងនាងមើលគ្រប់ពេលដែលនាងរលឹកមកឯង ... ! ចំណែកឪពុកនាងគេថារដ្ឋការក៏ចាប់គាត់យកទៅបាត់ទៅ ... នៅសល់តែម្ដាយនាង និងនាងប៉ុណ្ណោះ ក្រោយមក ... (កុសលហូរទឹកភ្នែករលីងរលោងរួចពោលទាំងឈឺចាប់ ) ម្ដាយនាងក៏មានជំងឺហើយក៏ស្លាប់ទៅ . , . បន្សល់ទុកឱ្យសុន្ទរីនៅម្នាក់ឯង ... ។ គ្នារស់នៅជាមួយនាងបានប្រហែលជិតមួយឆ្នាំ ... ។ ថ្ងៃមួយ ... ផែនការចាប់ចម្រាញ់ពួកសិស្សនិស្សិត ក៏ចាប់ទាំងខ្ញុំទាំងសុន្ទរីយកទៅដាក់សន្តិសុខ . . ជីវភាពពួកជាប់សន្តិសុខពេលនោះដុនដាបណាស់ ក៏ប៉ុន្តែសុន្ទរីត្រូវប្រធានសន្តិសុខជួយឧបត្ថម្ភម្ហូបអាហារគ្រប់គ្រាន់ ... នាងតែងចែករំលែកមកខ្ញុំពុំដែលភ្លេចឡើយ ... (ដល់ត្រឹមនេះកុសលឈ្លោកជីសប្រក់ទឹកភ្នែក) ... គួរឱ្យ

តស្មារ្យណាស់ . . . សម្ងាញ់ . . . នៅព្រឹកមួយនោះ . . . សុន្ទរីមានទឹកភ្នែករហោមរហាមមកលាគ្នាដើម្បីស្លាប់ . . . គ្នាក៏សួរដើមហេតុឡើង នាងឆ្លើយថាពីយប់មិញនេះ ប្រធានសន្តិសុខបានចាប់រំលោភនាងយ៉ាងព្រៃផ្សៃ តែខ្ញុំក៏បានពន្យល់ណែនាំលួងលោមនាងអស់រយៈពេលយ៉ាងយូរ ទើបនាងព្រម . . ។ មិនយូរប៉ុន្មាន . . . បានប្រហែលជាងបីខែប៉ុណ្ណោះ រឿងនេះក៏បែកធ្លាយខ្ចរខ្ចាយ . . . គេក៏ចាប់ប្រធានសន្តិសុខនោះទៅសម្លាប់ចោលទៅ . . . រួចគេរំសាយពួកជាប់សន្តិសុខទាំងអស់ឲ្យទៅនៅតាមភូមិផ្សេងៗ ពីមុន តាមការនឹកឃើញរបស់ពួកគេ ខ្ញុំក៏បែកគ្នាជាមួយសុន្ទរីពីគ្រឹមនោះមក ពេលបែកគ្នានោះ គ្នាគ្រាន់តែបានដឹងថាសុន្ទរីនាងមានផ្ទៃពោះ . . . តែក្រោយមកគ្នាក៏ពុំបានដឹងថានាងទៅនៅភូមិស្រុកណាទេ . . . ហើយកូននាងមិនដឹងជាប្រុសឬស្រី ? . . . បើតាមគ្នាស្មានមើលទៅ កូនសុន្ទរីគឺគីទីដែលឯងរើសចិញ្ចឹមនោះឯងមើលទៅ ! ព្រោះការរៀបរាប់របស់ឯងគឺនាងបានឆ្លើយថាប្ដីនាងជាឃាតករ . . . បើតាមយោបល់គ្នាគឺប្រាកដមួយរយភាគរយតែម្ដង !

អាស្នាអង្គុយស្ដាប់ការរៀបរាប់រឿងសុន្ទរីទាំងអួលអាក់ក្នុងចិត្ត ឃើញដូច្នេះ កុសលនិយាយលួងលោមសម្លាញ់គេ

- ណ្ហើយឈប់គិតទៅសម្លាញ់ !, រឿងកន្លងហួសទៅហើយ . . . យើងទុកដូចជាការយល់សប្ដិទៅចុះ ... យើងត្រូវបែរមើលមករឿងយើងចំពោះមុខនេះវិញ គេត្រូវជ្រើសរើសរកវិធីណាដើម្បីសម្រេចឲ្យបាន... ។



អាស្នាជូតទឹកភ្នែករួចប្រមូលអារម្មណ៍ឲ្យនឹងនរាចាទាំងមុខស្លូត ...

- គោះ ! សម្លាញ់ជូនគ្នាទៅមើលមន្ទីរពេទ្យម្ដង ! . . .

កុសលរអេះរអុញ ៖

- កុំអី ! សម្លាញ់ ! នាំតែញាំញាយមិនឆ្ងាញ់ទេ ! . . .

- អត់អីទេ ! កុសល ! . . . ខ្ញុំធ្លាប់ឃើញកន្លែងពេទ្យញឹកញាប់ដែរ

- តែកន្លែងពេទ្យនេះស្មោកគ្រោកណាស់ មនុស្សពិការរាប់មិនអស់ ! តែណ្ហើយ ! បើសម្លាញ់ចង់ឃើញហើយទៅក៏ទៅ ! . . .

ដោយប្រកែកមិនបានកុសលក៏ជូនអាស្នាទៅមើល . . .

- ខាងនេះពួកពិការ ! . . . ហើយខាងនោះពួករបួសថ្មីៗ ! . . ហើយខាងនោះទៀតពួកមានជំងឺគ្រុនចាញ់ ( កុសលចង្អុលប្រាប់ )

អាស្នាខំរកមើល . . . . យ៉ាងយកចិត្តទុកដាក់ ពីកន្លែងពិការ របួស រហូតមកដល់ពួកគ្រុនចាញ់ ! . . . គេហាក់ជំពាក់ភ្នែកមើលមនុស្សម្នាក់ដែលអង្គុយមាត់បង្អួច ! ក៏ងាកមកមើលបញ្ជាក់ម្ដងទៀត ! . . .

ស្រាប់តែគេព្រឺខ្លួនខ្លាក ! . . . ព្រោះអ្នកជំងឺនេះ គឺជាចិន្ត្រាប្អូនប្រុសគេ ! . . . គេស្ទើរតែស្ទុះទៅឱបក្ងាមដើម្បីបំបាត់ក្ដីរលឹក ! . . . តែចិត្តមួយបានឃាត់គេ ទើបគេនៅស្ងៀមទៅវិញ . . . គេងាកមកខ្សឹបដាក់ត្រចៀកកុសល កុសលងាកមើលតាមក៏ស្គាល់

- វានោះហើយ ! ឈ្មោះអាកំសត់ដែលពួកម៉ាកអាឫ និងខ្មោចអាមិននោះណា !

អាស្នាត្រេកអរណាស់ គេនាំកុសលទៅដាក់ផ្លាស់ប្តូរឃោបល-នៅបន្ទប់ផ្សេងឆ្ងាយពីទីនេះ . . .

– អាស្នា ! តើឯងគិតយ៉ាងម៉េច ? ពេលបានជួបប្អូនឯងយ៉ាងនេះ?

អាស្នាញញឹមបន្តិចទើបវាថា :

- គ្នាគិតឲ្យឯងប្រាប់ឲ្យវាមកជួបគ្នានៅទីនេះរាល់យប់ ដើម្បីបំពាក់បំប៉នស្មារតីវាណា ? តើឯងយល់ដូចម្តេចដែរ ?

- ត្រឹមត្រូវហើយសម្លាញ់ ! ពេលយើងបំពាក់បំប៉នប្អូនឯងបាន យើងបន្តការទាក់ទាញនេះតាមការជិតស្និទរៀង ៗ ខ្លួន ។

– ឃោបល់នេះល្អណាស់កុសល ! ដូច្នេះយើងចាប់អនុវត្តពីយប់ស្អែកទៅមែនទេ ?

- ត្រូវហើយ ! អញ្ចឹងយើងបែកគ្នាសិនទៅ . . .

* * *

កាលៈទេសៈដ៏តូចចង្អៀតពេលនេះមានតម្លៃណាស់ស្ទើរមួយវិនាទីក៏មានតម្លៃលើសលប់ដែរ . . . មួយវិនាទីស្លាប់ មួយវិនាទីរស់ . . . ។

ការឃោសនាអំពាវនាវតាមគោលនយោបាយ ១១ របស់អាស្នាបានទទួលជោគជ័យជាបន្តបន្ទាប់ . . . ។

ឥឡូវគេឃោសនាបាន ៨ នាក់ហើយ . . . គេត្រៀមតែថ្ងៃរត់ចេញ . . . ព្រោះបែកការណ៍ដោយលេចឮខ្លះខ្ចារដល់ប្រធានកង ។ គេនាំគស់ណាត់គ្នារត់ចេញនៅពេលយប់នេះឯង . . . ក៏ប៉ុន្តែយឺតពេលបន្តិច



ប្រធានកងក៏ចាប់អាស្នាហៅសេនយកទៅវាយសួរចម្លើយផ្ទាល់ :

- មើល៍ ! អាសេន ! ឯងប្រាប់អញឲ្យត្រង់មក ! តើនៅក្នុងផ្ទះបាយហោងស៊ិន ឯងទទួលការជាអ្វីដែរ ? . . .

គ្មានចម្លើយ . . . ប្រធានកងក្តៅចិត្តយ៉ាងខ្លាំងចំពោះសំនួរគ្មានចម្លើយរបស់វា . . . វាខឹងក្រេវក្រោធឡើងវាយវាត់អាស្នាយ៉ាងខ្លាំង..។

អាស្នាមិនឆ្លើយតបនឹងសំនួរវាមួយម៉ាត់សោះ . . . ប្រធានកងគំហក :

– អាសេន ! អ្អែងក្បាលរឹងណាស់ ! អ្អែងហ៊ានចូលមកបង្កភាពច្រលច្របល់នៅកន្លែងនេះ គឺអ្អែងទាមទារសេចក្តីស្លាប់ហើយ ! . . . អាប្អូន ! ឆាប់ឆ្លើយឲ្យត្រង់មកក្រែងបានរួចខ្លួនខ្លះ ! . . . តើសព្វថ្ងៃផែនការរបស់ចិនហោងស៊ិនធ្វើអ្វីខ្លះ ? . . . ឆ្លើយមក ! . . .

អាស្នាខាំធ្មេញក្រឹត ៗ រួចឆាកសម្លឹងមុខវាហើយស្តោះទឹកមាត់ដាក់មុខវា . . . ធ្វើឲ្យវាខឹងច្រឡោតគោកគូង វាយវាត់អាស្នាគ្មានត្រាប្រណី

ប្រធានកងចេញបញ្ជា :

-ឯណាមិត្តម៉ៅ ! ចូលមកវាយវាសួរចម្លើយមើល តើវាបញ្ចុះបញ្ចូលអ្នកណាខ្លះ ?

- បាទបង ! . . .

អាម៉ៅចូលមកដល់ច្រត់ចង្កេះសម្លឹងអាស្នាបញ្ចេញភាពឃោរឃៅរួចនិយាយមួយ ៗ ខ្លាំង ៗ :

- អាសេន ! . . . តើអ្អែងបញ្ចុះបញ្ចូលអ្នកណាខ្លះនៅក្នុងកន្លែង

នេះ ? . . .

អាស្នាផ្អួលក្រោបលើដីបើកភ្នែកសម្លឹងអាម៉ៅប្រធានកងតូច ស្មើរស្មុសាច់ហុតឈាម . . . រួចបន្លឺវាចាយ៉ាងម៉ឺងម៉ាត់ :

- ហ៊ឹះ ! . . . ពួកអាបិសាចស្រេកឈាម ! . . . ពួកអាឯងគង់តែថ្ងៃណាប្រជាជនទាំងអស់គេកាត់ថ្លៃក្បាលឯងមិនខានឡើយ . . . អាឯងចាំមើលទៅ ! ! . . .

អាម៉ៅវាយអាស្នាពីរបីពាក់រួចសើចកាចក :

- ហាស ! ហាស ! ហាស ! . . . ឯងកុំដេកយល់សប្តិ ! . . . ធ្លាក់ដល់ថ្នាក់នេះហើយ . . . បើសិនប្រៀបនឹងពូថៅវិញឈប់មុតទៅហើយអាខ្វាច . . . កុំចេះតែព្រុសផ្តេសផ្តាសនោះ !

អាស្នាងើបក្បាលសម្លឹងមុខអាម៉ៅយ៉ាងមុត រួចពោលយ៉ាងឈឺចាប់ថា :

- ហ៊ឹះ ! . . . អាតិរច្ឆាន ! . . . ពូថៅអញនេះរិលមុខអស់ហើយក៏ដោយ . . . តែ . . . អញមិនកាប់ឯងទទឹងសាច់ទេ ! ! . . អញ . . . ពុះ . . . ឯងបណ្តោយសាច់ . . . ឯងចាំមើលចុះ . . . អាឆ្កួតលេលា . . ក្រង់បែកឬមិនបែក . . . គង់តែដឹងទេ . . . អាឃាតករ ! . . . ។

ដូចកាប់ក្បាលមួយពូថៅ អាម៉ៅស្ទុះទាត់ធាក់អាស្នាគ្រប់ទិកន្លែងរហូតសន្លប់បាត់ស្មារតី . . . ។



ស្បៀងងឹតបានរយោនយកកំណើតសាជាថ្មីម្តងទៀត . . . ។

ល្ងាចនេះនៅជំរំបណ្តោះអាសន្ននេះគេបើកការប្រជុំរួមមួយ យ៉ាងអធិកអធម . . ។

នៅឯមន្ទីរឃុំឃាំងណោះ . . . អាប៊ូកំពុងនៅយាមអាស្នា . . . ដោយភាពប្រុងប្រយ័ត្ន . . ។

ស្រមោលខ្មៅមួយបានបន្សាត់ខ្លួនពីក្បែររោងមួយ ទៅរោងមួយរហូតដល់មន្ទីរឃុំឃាំង . . .

- អ្នកណាដើរចូលមក ! . . . ( អាប៊ូស្សូរតិច ៗ )

- ខ្ញុំកុសល ! . . .

- អូ ! ចូលមក . . .

មកដល់កុសលខ្សឹបប្រាប់ :

- យើងបានឱកាសហើយគិតចេញដំណើរឥឡូវនេះឯង ។ ចិន្ត្រានាំគ្នាប្រាំមួយនាក់ទៅចាំនៅដើមផ្លូវហើយ . . . តោះ ! ឆាប់ឡើង ! . . ដោះអាស្នា ! ភ្លាមមក !

អាប៊ូស្ទុះចូលទៅដោះអាស្នារួចហុចកាំភ្លើងមោឡ . . . ក៏ចាប់ចេញដំណើរភ្លាមមួយរំពេច . . . ។

អាស្នាត្រគាំត្រគាដោយបេត្រូវពួកវាវាយរាត់ពីថ្ងៃខ្លាំងពេក ដើរពុំសូវរលៀន . . . ចិន្ត្រាឃើញបងយ៉ាងនេះ មានចិត្តអាណិតយ៉ាងខ្លាំងទើបស្ទុះចូលទៅជួយគ្រាហ៍បងទាំងស្រួងចិត្តឈឺចាប់ខ្លោចផ្សា :

- បងឲ្យកន្សែងខ្ញុំស្តាយឲ្យ ! បងដើរខ្លួនទទេទៅ ! .. ( ចិន្ត្រាពោលទៅកាន់អាស្នា ) ..

- បានហើយ !... ប្អូន ... បងដើររួចទេ ប្អូនកុំព្រួយអី !...

ចិន្ត្រានៅតែបេះយកកន្សែងមកស្តាយ ហើយកៀកជាប់ជាមួយបងរបស់គេ ។

ដំណើរកៀសខ្លួនរបស់ជនភ្ញាក់ស្លឹកទាំង ៨ រូប រួមជាមួយអាស្នាផង ... បានទ្រតរះបំផុត ដែលមានកុសលនិងបិត្តុប ជាអ្នកនាំផ្លូវ ...។

ការធ្វើដំណើររស់រយៈពេលមួយយប់ទើបគេចូលទៅឈប់សម្រាកនៅក្បែរមាត់វាលមួយ ដើម្បីដាំបាយបរិភោគ ។

ឥឡូវនេះម៉ោងប្រហែលជិតប្រាំបួនហើយ ... គេរៀបចំចេញដំណើរ ស្រាប់តែគេក្រឡេកឃើញពួកអាម៉ៅមួយក្រុមប្រមាណគ្នា ២៥ នាក់ កំពុងស្រូតដំណើរយ៉ាងលឿនក្បែរកន្លែងពួកគេសម្រាក ... ពួកគេទាំងនោះខំដំអក់យ៉ាងស្ងៀមស្ងាត់និងប្រុងប្រយ័ត្ន រហូតពួកវាដើរហួសអស់ទើបចេញដំណើរគេចពីផ្លូវនោះទៅផ្លូវផ្សេងទៀត ...។ ម្តងនេះ ... គេស្រូតដំណើរលឿនជាងមុន ... ។

រយៈពេលធ្វើដំណើររស់ពេលពីរយប់បីថ្ងៃហើយ ... គេក៏បានមកដល់ជាយដែនស្រុកពិព្រែង ... ហើយ អាស្នាសួរទៅកុសល :

- កុសល ... បើទៅដល់ពេលសម្លាញ់ ធ្វើប្រជាឥតម្ចាស់ធ្វើកងទ័ព ? ...



កុសលដើរបណ្តើរឆ្លើយបណ្តើរ ...

- បើតាមចិត្តគ្នា ... គ្នាគិតឈប់នៅផ្ទះចុះ ព្រោះគ្នាព្រាត់ឪពុក ម្តាយច្រើនឆ្នាំហើយ ...!

- ចុះចិន្ត្រា ! តើប្អូនធ្វើអ្វីដែរ ? ...

ចិន្ត្រាញញឹមខ្ទប់ទើបឆ្លើយ :

- ខ្ញុំចង់រៀនទៀត តែហួសអាយុបន្តិចហើយ !!

- មិនទាន់ហួសពេលទេ ប្អូន ... ឲ្យតែប្អូនប៉ងប្រាថ្នាគង់តែបានសម្រេច ... ! ( អាស្នាឆ្លើយតប )

ដើរបណ្តើរនិយាយគ្នាបណ្តើរដោយក្តីសង្ឃឹម ... ។

ថ្ងៃត្រង់ជាក់ដោយស្រេកទឹកខ្លាំងពេក អាស្នាឈឺខ្លួនផងក៏ពោលឡើង :

-ថ្ងៃក្តៅណាស់ ! ខ្ញុំស្រេកទឹកស្ទើរអត់ពុំបាន ...

ដោយទឹកករុណាពីបង ចិន្ត្រាឆ្លើយ

-ទ្រាំបន្តិចទៅបង ! ... ចាំដល់មួយត្រពាំងខាងមុខ ចាំខ្ញុំទៅដងទឹកត្រពាំងខាងកើតមកឲ្យបង ... !

- ម៉េចក៏អូនស្គាល់ត្រពាំង ? ( អាស្នាសួរចិន្ត្រាដោយឆ្ងល់) ។

-ខ្ញុំធ្លាប់ចេញចូលកន្លែងនេះញឹកញាប់ណាស់ ទើបតែខានដែលពេលអាពតសាប់ទេ

រំពេចនោះ ... បិត្តុបមដំណើរម្នាក់ឲ្យសញ្ញាកកន្លែងពួន ព្រោះ

នៅខាងមុខមានពួកចោរព្រៃប៉ុលពតមួយក្រុមកំពុងដើរតម្រង់មក គេទាំងអស់ប្រញាប់រកកន្លែងពួន ... មួយស្របក់ពួកវាក៏មកដល់ ហើយដើរហួសទៅ ។

អាស្នាសួរទៅមិត្តរួមដំណើរទាំងអស់ :

- តើពួកគេទាំងនោះនៅកងណាដែរបានជាត្រឡប់ទៅនោះវិញ ?

ចិន្ត្រាឆ្លើយ :

- ពួកនេះត្រូវឡើងទៅជួរកម្លាំង ! ... នៅជំរំ ១០០១ វាជាកងអាម៉ុក .. អាមួយកាំភ្លើងខ្លីដើរក្រោយនោះ គឺប្រធានកងតូចរបស់វាជាអតីតប្រធានសន្តិសុខនៅភូមិភាគពាយ័ព្យ ។

ក្រោយពួកវាទៅផុតអស់ គេក៏ចេញមក ហើយដើរសំដៅបុប ទ្រាំងដែលដៅទុក ។ ដល់ភ្លាមចិន្ត្រាជាមួយមិត្តបួក៏ទៅផងទឹកត្រពាំង ... ទៅបាត់មួយស្របក់ .. ស្រាប់តែឮស្នូរកាំភ្លើងលាន់ព្រោះ ។ ប្រហែលពីរបី ។ គេទាំងអស់នាំគ្នាក្រោកឈរ ... សម្លឹងកន្លែងបាញ់ ! ស្រាប់តែគេឃើញចិន្ត្រាត្រូវមិត្តបួគ្រាហ៍ដៃម្ខាង ... ហើយបាញ់តបកដៃម្ខាងទៀត ... ឃើញដូច្នេះគេទាំងអស់ស្ទុះចូលទៅជួយព្រមគ្នា ភ្លាមនោះ ... ពួកវាបញ្ចេញខ្លួនរត់ដេញតាមមិត្តបួ និងចិន្ត្រាព្រោងព្រាត ។ យល់ភាពអាសន្ន អាស្នាក៏បញ្ជាឲ្យបំបែកគ្នាពីរ ។ នាក់ ដើម្បីបាញ់រំដោះយកមិត្តបួ និងចិន្ត្រា ... ។ ឆាកប្រយុទ្ធរួសរាន់បន្ទាយមួយស្របក់ ទើបគេរំដោះបានចិន្ត្រានិងមិត្តបួ ម្នាក់ ។ បាញ់ចង់អស់គ្រាប់ក៏ប្រញាប់នាំគ្នាគេច



ខ្លួនភ្លាមដោយគ្រាហ៍ចិន្ត្រាផ្ទាល់គ្នា ។

អាស្នា ភិតភ័យនឹងរបួសរបស់ចិន្ត្រាណាស់ ... គេខំគ្រាហ៍ផង បង្អោបកប្អូនផងទាំងដួងចិត្តអាណិតប្អូនស្ទើរខ្ទេចចិត្ត ។

- ចិន្ត្រា ! ។ ក្នុងខ្លួនអូនយ៉ាងម៉េច ?

ចិន្ត្រាខំនិយាយតបទៅបងវិញទាំងត្រដាបត្រដួស

- អត់ ... អី ... ទេ ... បង !

ចំណែកកុសលព្យាយាមចាក់ថ្នាំចិន្ត្រាជាញឹកញាប់ ដោយកម្លាំងចិន្ត្រាកាន់តែខ្សោយ ក៏នាំគ្នាកាប់ស្នែងសែងចិន្ត្រាផ្ទាល់គ្នាតម្រង់មកទិសស្រុក ។

កន្លះម៉ោងក្រោយមកចិន្ត្រាស្រេកទារទឹកផឹក ...

- បងអាស្នា ! ... បងមកជិតខ្ញុំបន្តិចមក ! អូយ ! ស្រេកទឹកណាស់ ! ...

អាស្នាស្ទុះចូលទៅជិតប្អូនរួចខ្សឹបសួរកុសល :

- យ៉ាងម៉េចសម្លាញ់ ? តើរបួសប្អូនខ្ញុំអាចទប់ទល់ឬយ៉ាងម៉េច ?

កុសលក៏លូកដៃស្ទាបចិន្ត្រាមួយស្របក់ ទើបប្រែមុខហើយងាកមកប្រាប់អាស្នាទាំងមុខក្រៀមក្រំហើយគ្រវីក្បាលមួយៗ :

- អាស្នា ! សម្លាញ់ ! ... របួសប្អូនឯងតាមគ្នាពិនិត្យមើល ... គឺត្រូវដាច់ចុងថ្លើមហើយ ... បើតាមកម្លាំងជីពចរ ចុះខ្សោយណាស់ហើយសម្លាញ់ ! ... សម្លាញ់គិតមើលទៅ ... គ្មានសង្ឃឹម

ទេ . . . ! ក្រែងចិន្ត្រាផ្ដាំយ៉ាងម៉េច ? ឆាប់ឡើង !

អាស្នា យាត់អ្នកសែងរួចទៅជិតប្អូនទាំងតក់ស្លុត . . .

- ចិន្ត្រាអូន ៗ ! . . . អូនយ៉ាងម៉េចទៅហើយ !

ចិន្ត្រា . . . ខំនិយាយខ្សាវ ៗ មកកាន់បង :

- បង . . . សម្លាញ់ ! . . . ប្អូនមិនអាចរស់តទៅទៀតបានទេ ! . . . សូមបង សងឈាមឱ្យប្អូនផង ! . . . ឃាតករដែលបាញ់ប្អូនអម្បាញ់មិញគឺអារ៉េវណ៉ាបង ! . . .

ចិន្ត្រាលើកដៃដាក់លើស្មាបង រួចពោលថ្នម ៗ :

- បង . . . អាស្នា ! សូមបងរស់នៅ ឱ្យបានសេចក្ដីសុខ និងទទួលជ័យជំនះគ្រប់ពេលទាំងអស់ . . . អូន ! លាបង . . . ហើយ!

- ពុទ្ធោ ! ។ ចិន្ត្រា ! ។។។។ ប្អូនសម្លាញ់ចិត្តបង ! . . . ប្អូនស្លាប់ចោលបងហើយ ចិន្ត្រា . . . អូន ! . . . អូនអភ័ព្វណាស់ ! បងខំ . . . កសាងជ័យជំនះគ្រប់ឧបសគ្គដើម្បីតែរូបអូន ឥឡូវ ! . . . អូនស្លាប់ចោលបងហើយ ! . . .

អាស្នាយំខ្សឹកខ្សួលលើសពចិន្ត្រាគួរឱ្យសង្វេគ មិត្តរួមដំណើរទាំងអស់យំសោកអាណិតចិន្ត្រាស្ទើរដាច់ថ្លើមព្រមាត់ ។

មិត្តបូនិយាយទាំងទឹកភ្នែកហូររហាម :

- ចិន្ត្រាសម្លាញ់ ! . . . ឯងមិនគួរអាយុខ្លីសោះ ! យើងធ្លាប់រួមសុខរួមទុក្ខជាមួយគ្នា . . . ឥឡូវ . . . នៅសល់តែគ្នាម្នាក់ឯកក្នុង



ចំណោមគ្នាបីនាក់ . . . ។ ចិន្ត្រា ! . . . សូមវិញ្ញាណក្ខន្ធឯងបានទៅកាន់សុគតិភពកុំបីអាក់ខានឡើយ . . . គ្នាសម្រេចចិត្តត្រូវតែសងឈាមជួសឯងឱ្យបានដាច់ខាត ! . . . ។

អ្នកទាំងអស់យំទល់មុខគ្នាទាំងឈឺចាប់ . . . បន្ទាប់មក . . . គេក៏សែងសពចិន្ត្រាមកដល់ភូមិស្រុក . . . ហើយរៀបចំធ្វើបុណ្យយ៉ាងសមរម្យតាមប្រពៃណីខ្មែរ . . . ។

ចំណែកបងប្អូនជនរងគ្រោះផ្សេងទៀត ក៏ត្រូវបានរដ្ឋអំណាចជួយទំនុកបម្រុងគ្រប់បែបយ៉ាងនិងយកចិត្តទុកដាក់យ៉ាងសមរម្យ ។ ក្រោយពេលចប់ពិធីបុណ្យសព្វគ្រប់ អាស្នាក៏បបួលកុសលទៅកន្ទែងគេ . . .

ទៅដល់ បញ្ជាការស្រុកអរណាស់ . . . ក៏បង្កើតកូនពិធីជប់លៀងមួយដើម្បីអបអរដល់ការវិលត្រឡប់ដោយជោគជ័យរបស់អាស្នា . . . បញ្ជាការបានសាកសួរដើមទងរហូតដល់ចប់ ហើយក៏ដាក់ផែនការមួយឱ្យអាស្នាបំពេញ . . .

- តើមិត្តអាចបំពេញបានទេ ! លើការពួនស្ទាក់ផ្លូវខ្មាំងដែលវាធ្លាប់ចេញចូលក្នុងស្រុកយើង ?

- ខ្ញុំអាចបំពេញបាន ! . . . ព្រោះខ្ញុំអាចក្ដាប់បានផ្លូវឡើងចុះញឹកញាប់របស់ពួកវា ! . . .

- ស្រួលហើយបើអញ្ចឹងត្រៀមខ្លួនទៅ ថ្ងៃចេញដំណើរចាំខ្ញុំអោយដំណឹង ! . . .

- ជាទបង . . .

- លើកនេះបក្ខងដត្រូវដឹកនាំទ័ពផ្ទាល់ ហើយសហការជាមួយគងទ័ពវៀតណាមផងណា ! . . .

- ទទួលបញ្ជា ! . . .

ពិធីជប់លៀងល្ងាចនេះបានចប់សព្វគ្រប់ក្រោយការរីករាយ និងសាទរការ ។

កុសលបានបបួលអាស្នាទៅលេងផ្ទះគេ :

- អាស្នា ! . . . តោះទៅលេងផ្ទះខ្ញុំពីរបីថ្ងៃ . . . ចាំចេញទៅស្នាក់ខ្ទាំងទាំងអស់គ្នា ! ម៉េចញញឹមញញុំ អីទៀតទៅ ! . . .

- អញ្ចឹងក៏បាន ! ទៅក៏ទៅ (អាស្នារាងស្ទាក់ស្ទើរ) ផ្ទះឯងនៅឆ្ងាយដល់ណាកុសល ?

- មិនឆ្ងាយទេ នៅម្ខាងស្ទឹងខាងនោះ . . . ក្បែរវត្តស្វែងពេក ឯងស្គាល់វត្តស្វែងទេ ?

- ថមិនស្គាល់ ! នៅទីនោះគ្នា . . (អាស្នាញញឹមមានន័យ)

- គ្នាយ៉ាងម៉េច ? ( កុសលសួរបញ្ជាក់ ) ។

- កុំចង់ដឹងអី . . . !

- ទេ ! ប្រាប់គ្នាសិនមក !

- ណ្ហើយតោះ ! . . ដើរផងនិយាយផងទៅ ! . .

- ឯងមានរឿងអីអាស្នា ! ប្រាប់គ្នាផងបានទេ ?



- បាន ចាំគ្នាប្រាប់ ! . . ។

អាស្នាងាកមើលទាយអាយបន្តិចទើបនិយាយបន្ត ៖

- កាលដែលគ្នាបោះជើងនៅទីនេះ . . . គ្នាបានជំពាក់ចិត្តលើនារីម្នាក់នៅក្បែរវត្តស្វែងនោះឯង . . !

- អូ ! អញ្ចឹងស្រួលហើយ ! . . ទៅលេងផ្ទះគ្នាផង . . . ទៅលេងផ្ទះ . . . នារីនោះផងមែនទេ ? . . . ត្រូវហើយ ! . . . តើនារីនោះស្អាតយ៉ាងណា ? ស្អាតជាងសុន្ទរីឬអាស្នា ? . . .

- គ្នាមិនហ៊ានរួតទេ ! . . . បួសដោយវត្ត . . . ចិត្តដោយខ្លួនឃ្លានឆ្ងាញ់ស្រឡាញ់ល្អ បើឯងចង់ឃើញ . . . គ្នាឲ្យឃើញតាមរូបថតសិនចុះ ដើម្បីព្រាងត្រួស ។ . . . ។ តាមចិត្តគ្នាចង់តែទៅឲ្យដល់ភ្លាមតឡូវ តែបានរូបថតនេះជួយទប់ទល់ ក៏ធូរមួយគ្រាដែរ ។

និយាយបណ្ដើរហុចរូបថតឲ្យកុសលបណ្ដើរ . . . កុសល . . . ភ្ញាក់ព្រើតបើកភ្នែកធំ ៗ . . . ងើបមើលមុខអាស្នា ដោយហួសចិត្តក៏សួរអាស្នា :

- តើនារីនេះឈ្មោះអីដែរអាស្នា ?

- អូ ! នាងឈ្មោះ ណែ . . . សុធា . . . និយាយចំឈ្មោះអញ្ចឹងដើមទ្រូងគ្នាញ័រខ្ទុកខ្ទាក់ ៗ " . . ទឹកគេស្ទើរតែទៅដល់លេបតែម្ដង ! . . .

កុសលផ្ទៃមុខស្លេកហុចរូបថតឲ្យអាស្នាវិញដោយគ្មាននិយាយស្ដីអ្វី

មួយម៉ាត់ទៀយ ... ទៅជិតដល់ អាស្នាសួរកុសលទៀត ៖

- សម្លាញ់ ! ... ឯណាផ្ទះឯងមួយណា ?

- នោះធំ ! ផ្ទះគ្នា ! មានដើមចឹកដោះមុខផ្ទះនោះណ៎ា ! ... (កុសលចង្អុលបង្ហាញ) ។

- អូ ! ... ឃើញហើយ ... ណែ ! ... ឯងចូលផ្ទះឯងចុះណ៎ា ! គ្នាហួសទៅផ្ទះសង្សារគ្នាហើយ ! ... ចាំយប់ជ្រៅបន្តិចគ្នាមករកឯងវិញណ៎ាសម្លាញ់ ។

- អើ ! ... ទៅចុះ !

អាស្នាត្រហេបត្រហបទៅ បន្សល់ទុកឲ្យកុសលឈរសម្លឹងពីក្រោយខ្នងទាំងលួចញញឹម ។ ទៅដល់សុធាកំពុងបោសផ្ទះ ក្រឡេកឃើញអាស្នាក៏រត់មកទទួល ...

- បងអាស្នា ! មកពីយុទ្ធនាការហើយឬ ?

- មកវិញហើយសុធា ! លោកអ៊ំប្រុសលោកអ៊ំស្រីទៅណាហើយ ?

- អូ! ...គាត់ណែអញ្ជើញទៅលេងឯចុងភូមិខាងជើងឯណោះ!។ ចុះបងទៅយុទ្ធនាការឯណាក៏យូរម្ល៉េះ ? ខ្ញុំចាំតែទៅសួររកបងមិនឃើញ ហើយគេទាំងអស់ទៅគ្រប់គ្នា ចាត់តែបងម្នាក់ឯង !

អាស្នាក៏រៀបរាប់សព្វគ្រប់ប្រាប់សុធា ធ្វើឲ្យសុធាភិតភ័យជំនួស ... ។

- បងចាំញាំបាយនេះហើយ ! បន្តិចទៀតពុកនិងម៉ែអញ្ជើញមក



ហើយ ! អង្គុយលេងចុះ ចាំខ្ញុំបង្កាត់ភ្លើងដាំបាយថែមទៀត ... ។

មួយស្របក់ធំ ឪពុកម្តាយសុធា មកដល់ល្មម ។

- អើ ! សុធា ! សុធាអើយ ! ..

- ចាស ! ពុក ! ខ្ញុំនៅឯក្រោយឯនេះ ! .

- មកនេះមួយភ្លែតកូន ! . ឲ្យឆាប់ឡើង ! .

- មានការអីក៏ប្រញាប់ប្រញាល់ម្ល៉េះ . . ម៉ែ ? . . .

- ឯណោ . . . បងប្រុសឯង ! ថាមកនោះ ! ម៉េចមិនឃើញ ?

សុធាធ្វើមិនដើ ញ៉ិមញ៉ុម ៗ :

- ទេ ! . . មានបងប្រុសឯណាម៉ែ ? . . . មានតែបងអាស្នា ទេ ! . . . គាត់ទើបតែមកពីយុទ្ធនាការ គាត់មកលេងមុននេះបន្តិច . . នោះគាត់ទៅអង្គុយលេងនៅមាត់ស្ទឹងឯណោះ (សុធាលើកដៃចង្អុលបង្ហាញម្តាយឪពុក) . . . ។

- មិនមែនអាស្នា ទេ ! គេប្រាប់ម៉ែថាបងកូនឯងមក ! . . ទើបម៉ែនាំពុកឯងប្រញាប់ប្រញាល់មករកនេះណ៎ា ! .

ក្រែង . . . គេច្រឡំនឹងបងអាស្នា . . . ទេដឹង . . . ពុក !

- ទេ ! គេប្រាប់ពុកប្រាកដណាស់ណ៎ា ! (ឪពុកសុធាប្រកែក)

- បងណាមួយ ? . . បងដែលទៅ ក ៥ នោះឬពុក ? . .

- មិនមែនទេ ៗ ! បងកូនឯង . . . កុសល ! ដែលទៅរៀននៅសៀមរាប ហើយភៀសមកបែកគ្នាពីឆ្នាំ ១៩៧៥ នោះណ៎ា ! .

- ពិតមែនឬពុក ? ... បើមកលេចក៏មិនឃើញ ? ... ខ្ញុំសង្ស័យតែគេប្រឡំនឹងបងអាស្នាទេ !

- មិនសម អ៊ី ឯងកុហកទេ ... គាត់ប្រាប់ច្បាស់ណាស់ !

- ក្រែងលោមកនៅផ្ទះពួកត្បូងទេដឹងពុក ? ...

- មិនដឹងដែរ !.. គាត់ប្រាប់ថាមក។ មិនដឹងនៅឯណា ?

ក្រោយនោះអាស្នាក៏មកដល់ល្មម ...

- ជម្រាបសួរអ៊ំប្រុស អ៊ំស្រី !

- អើ ! លើកដៃថ្វាយព្រះ ក្មួយសុខសប្បាយទេឬ ? ..

- បាទអ៊ំ សុខសប្បាយទេ ! . អ៊ំទើបអញ្ជើញមកពីណា ?

- អូ ! អ៊ំទើបមកពីសួររឿងទូកក្ដារគេ ឯចុងភូមិខាងជើងឯណោះ.. ទទួលឮគេថាកូនអ៊ំមកក៏ ... នាំម៉ែវារវៀសវៃមកក្រោយនេះណ៎ា ! ..

អាស្នាធ្វើមិនយល់ ងាកមើលមុខសុធា

- កូនណា .. លោកអ៊ំ ?

- អូ ! កូនអ៊ំ ! បងសុធា .. ដែលរៀននៅសៀមរាប ហើយជៀសមកបែកគ្នា ... មិនមែនមួយដែលទៅ ក ៥ នោះទេ !

- បើអញ្ចឹង ! . បងដែលភ្ជោះជាមួយសុធានោះឬ ?

- ហ្នឹងហើយ ! ក្មួយ .. ! . កូនមួយហ្នឹង ... ព្រាត់គ្នា តិតទៅ ជិតដប់ឆ្នាំហើយ ...

- ខ្ញុំភ្លេចសួរឈ្មោះ ... តើគាត់ឈ្មោះអ្វីដែរអ៊ំ ?



- វាឈ្មោះកុសល .. ណ៎ាក្មួយ !.

- យី ! .. កុសល ! ... (អាស្នាបើកភ្នែកធំ។ ធ្វើស៊ីហាក់ដូចមនុស្សបាត់កាត) ។

- យ៉ាងម៉េចបងធ្លាប់ស្គាល់គាត់ឬ ? ...

អាស្នាងាកមើលមុខសុធាដោយក្ដីខ្មាសអៀន មុខឡើងក្រហមមិនឆ្លើយតប ។

- ក្មួយដែលធ្លាប់ឮឈ្មោះនោះឬ ?

អាស្នាអេះអុញ ៗ រកឆ្លើយមិនរួចតក់ក្ដុប ៗ ... គាប់ជួនពេលនោះកុសលក៏មកដល់ល្មម ...

- យីកុសល ! កូន ! កូនអាយុវែងណាស់ !

- បង ! កុសល ! .. ខ្ញុំនឹកបងណាស់ .. ! ខ្ញុំស្មានតែបងស្លាប់បាត់ទៅហើយ ... ។

- ជំរាបសួរពុក .. និងម៉ែ .. !

- អើ .. អាយុវែងណាកូន ! .

- យីសុធាឥឡូវ ... ធំសន្ធឹកណាស់ !

- ក្មួយអាស្នា .. នេះហើយកូនខ្ញុំនោះ ... ទទួលស្គាល់រាប់អានគ្នាទៅណ៎ា ! .. មើលមុខកុសលនិងសុធា សឹងតែបះបិទ មែនទេអាស្នា ?

អាស្នាហួសចិត្តបែរជាស្ងើចញ៉ឹម ៗ ដាក់កុសល រួចរពាពាក្យឡើងទាំងអៀនខ្មាស ៖

- គ្នាគិតលាឯងទៅកន្លែងវិញហើយសម្លាញ់ ! . .

- ទៅៗទៅមិនបានទេ.. ក្រែងឯងបបួលគ្នាមកលេងផ្ទះ អី...ណែ !

អាស្នាឆាប់ឆ្លើយគាត់

- គ្នាមានការបន្តិច . . : ត្រូវជួបបញ្ហាការ . . . !

កុសលសើចញឹម ៗ ដាក់អាស្នា

- សម្លាញ់ធ្វើអញ្ចឹងមិនកើតទេ ! . . . វាយ៉ាងម៉េចក៏យ៉ាងម៉េចទៅ ! គ្នា . . . រឹតតែត្រេកអរណាស់ទៅទៀត . . . ។

ឪពុកម្តាយ និងសុធា ទឹកឆ្ងល់នឹងសំដីកុសលជាមួយអាស្នាណាស់ តើគេស្គាល់គ្នាពីកាលណា បានជាហៅគ្នាសម្លាញ់ ៗ ! . . . អ៊ំប្រុស អ៊ំស្រី និងសុធាមើលមុខគ្នាឡើងឡង់ ៗ . . . ។

ពុកម៉ែនិងសុធា ... កុំឆ្ងល់អី ! ... អាស្នានេះត្រូវជាមិត្តរួមថ្នាក់របស់ខ្ញុំ ហើយជាមិត្តស្និទ្ធស្នាល ... របស់ខ្ញុំទៀត . . . ថ្មីៗ នេះគេមានគុណចំពោះកូនណាស់ ! ...ដោយគេបានទៅរំដោះកូនឲ្យរួចផុតពីដៃពួកខ្មាំងទៀត . . .។

ដោយដឹងថាអាស្នាជាមិត្តសម្លាញ់របស់កុសល ឪពុកម្តាយកុសលរឹតតែសប្បាយចិត្តថែមទៀត ប្លែកតែសុធា . . . នាងខ្មាសឡើងមុខក្រហមប្រៀបដូចព្រះអរុណពេលព្រលឹម . . . រួចរត់ឡើងលើផ្ទះចូលក្នុងបន្ទប់បាត់ទៅ . . . បន្សល់ទុកឲ្យអ្នកចំណូលថ្មី និងញាតិមិត្តជិតឆ្ងាយជួបជុំសួរសុខទុក្ខ និងរឿងពិសាបាយយ៉ាងរីករាយ . . . ។



សុធានាងលួចត្រេកអរក្នុងពោះ . . . តែនាងលាក់ជាមួយបងប្រុសនាងមិនឲ្យដឹង ប៉ុន្តែកុសលដឹងរួចមុនទៅហើយ . . . ។

ការសប្បាយរីករាយនិងការជួបជុំក្រុមគ្រួសាររបស់គ្រួសារកុសលបានប្រព្រឹត្តទៅអស់រយៈពេលបីថ្ងៃ . . . ក៏ដល់ពេលត្រូវចេញស្ទាក់ផ្លូវខ្មាំងចុះពីភ្នំ... ។ ចេញដំណើរលើកនេះកុសលបានរួមដំណើរជាមួយអាស្នា ។

អ្នកដែលនាំផ្លូវគឺមិត្ត ឬ . . . អាស្នា និងកុសល . . . នៅពេលទៅជិតដល់ . . . កន្លែងខ្មាំងធ្លាប់ឆ្លងកាត់ហើយក៏បំបែកគ្នាជាមួយកងទ័ពវៀតណាម . . . ដើម្បីងាយស្រួលក្នុងការវាយលុកយកជ័យជំនះលើពួកខ្មាំង . . . ។

អាស្នាបានប្រជុំកូនទាហានទាំងអស់ដើម្បីបំភាក់បំប៉នស្មារតី .

- មិត្តទាំងអស់ត្រូវប្រុងប្រយ័ត្នឲ្យមែនទែនហើយត្រូវដាច់ខាតចំពោះខ្មាំង ! . . . នៅលើសមរភូមិប្រយុទ្ធ មិត្ត . . . ទាំងអស់ . . . ត្រូវស្តាប់បញ្ជារបស់ខ្ញុំដាច់ខាត ! . . . ឥឡូវជិតភ្លឺហើយ . . . យើងត្រូវដើរតាមផ្លូវនេះនេះ . . . ទៅនៅចាំស្ទាក់បាញ់ត្រង់ម្តុំកូនត្នោតដុះច្រើនខាងមុខនេះបន្តិច . . . ពួកកងទ័ពវៀតណាម គេបានទៅនៅពីខាងអូរខាងណោះ ! ដើម្បីវាយសម្រុកបំបាក់ស្មារតីខ្មាំង . . . !

លុះរៀបចំរួចហើយ . . . ការរង់ចាំនេះរឹតបាត់ តាំងពីភ្លឺព្រាង ៗ រហូតភ្លឺច្បាស់ . . . នៅតែមិនឃើញ ថ្ងៃរះផុតចុងឈើ . . . ក៏ដូចវែកបង្ហួសលម៉ោង . . . ងងាយទាងកើត . . . ពួកក្បត់មួយក្រុមក៏ចុះដើរ

មកតាមផ្លូវនេះដោយភាពប្រុងប្រយ័ត្ន . . . ។

ការរង់ចាំរបស់អាស្នាយូរពេក . . . ដោយធ្លាប់ដឹងថាខ្មាំងតែងឆ្លងតែពេលភ្លឺព្រាង ៗ ឥឡូវថ្ងៃរះពេញពន្លឺហើយ . . . នៅតែមិនឃើញ ទើបអាស្នាក្រោកដើរចេញទៅមុខបន្តិច លុះដើរបានបន្តិច ជិតដល់ផ្លូវនេះកែង . . . ពួកខ្មាំងឃើញអាស្នាក៏ក្រាបស្ងាត់ផ្អើលអាស្នា . . . អាស្នាពុំបានឃើញក៏លើកដៃឲ្យសញ្ញាពួកទាហានទាំងអស់ដើរតាមពីក្រោយ . . . គ្រាន់តែអាស្នាដើរចូលជិតដល់ទៅប្រមាណ ៣០ ម៉ែត្រពួកវាស្រែកបញ្ជា!

- នៅឲ្យស្ងៀម ! . . . លើកដៃ ! . . .

អាស្នាភ្ញាក់ព្រើតងាកមើលឆ្វេងស្តាំឃើញសុទ្ធតែពួកខ្មាំងកំពុងក្រាបបែរចុងកាំភ្លើងមករកគេទាំងអស់ ! . . . អាស្នាក៏លើកដៃ . . . ជាមួយនោះដែរ ពួកទាហានទាំងអស់ក៏ប្រះខ្លួនផ្តួលហើយបែរចុងកាំភ្លើងមករកពួកខ្មាំងវិញដែរ ។ ខ្មាំង . . . ស្រែកបញ្ជាជាថ្មីម្តងទៀត . . .

- ដាក់អាវុធទាំងអស់គ្នាភ្លាម ! . . . បើមិនព្រមដាក់ទេ ! . . . ប្រយ័ត្នអញបាញ់ ! . . . អាម្នាក់នេះសម្លាប់ចោលណា ! . . . ឆាប់ឡើងៗ ! . . . (ពួកខ្មាំងតៀនយ៉ាងរន្ធើន)

កូនទាហានទាំងអស់ ! . . . អេះអុញមិនដឹងគិតដល់បញ្ជាការខ្លួន បម្រុងទម្លាក់អាវុធ ។ ចំណែកកុសលភ័យណាស់ចំពោះអាយុជីវិតរបស់មិត្តគេ ក៏ងាកខ្សឹបជាមួយមិត្ត ឮ ។

- តើយើងគិតដូចម្តេចបើវាដល់ថ្នាក់នេះហើយ . ?



- មិត្តឮមិនទាន់ឆ្លើយផងខ្មាំងបញ្ជារន្ធើនម្តងទៀត . . . ។ ភ្លាមនោះអាស្នាងាកមករកមិត្តឮ និងកុសល និងកូនទាហានទាំងអស់ ទាំងទឹកមុខញញឹម និងកក់ក្តៅ . . . រួចចេញបញ្ជាយ៉ាងម៉ឺងម៉ាត់ដាច់ខាត ! . . .

- មិត្តទាំងអស់គ្នាកុំគិតពីជីវិតខ្ញុំឲ្យសោះ ! . . . ត្រូវស្តាប់បញ្ជាខ្ញុំដាច់ខាត . . . បាញ់ ! ! ! . . .

អាស្នាបញ្ជារួចផ្តួលខ្លួនទៅលើដីជាបន្ទាន់ . . . ប៉ុន្តែហួសពេលទៅហើយ គ្រាប់ពីរគ្រាប់បានមកទម្លុះស្មារបស់គេមួយគ្រាប់និងមួយគ្រាប់ទៀតត្រូវត្រង់ជិតកណ្តៀតក្លួម.. ធ្វើឲ្យគេដួលវិលខ្វាល់...ទៅលើដីយ៉ាងខ្លាំង ការប្រយុទ្ធគ្នា បានចាប់ផ្តើមយ៉ាងខ្លាំងក្លា . . . សូរគ្រាប់កាំភ្លើងលាន់ដូចផ្គរធ្លាក់ពីលើភ្នំ . . . គ្រាប់ដូចទឹកភ្លៀងស្រោចគ្នាទៅវិញទៅមក ...។

ភ្ញាក់ពីសន្លប់អាស្នាស្រវាកាំភ្លើងបាញ់តបខ្មាំងវិញយ៉ាងក្លាហាន .. ឈាមដោកដ៏គេមិនគិតពីជីវិតគេទេ ... គេបែរជាចេញបញ្ជាម្តងទៀត... ឡើងខាងឆ្វេង ! . . . ខាងស្តាំបាញ់រះ ! . . . ដោយឮសំឡេងអាស្នា . . . កុសលអរព្រួចប្រមូលស្មារតីភាពប្រយុទ្ធបាញ់រះលើសត្រូវយ៉ាងពេញទំហឹង . . . តែឡើងពុំរួចសោះ ព្រោះខ្មាំងមានគ្នាច្រើនពេក ហើយវាបាញ់សម្រុកលើសលប់ . . . ស្តាប់ទិសតំបន់អ្វីមិនឮសោះ . . . បង្ខំឲ្យកុសល និងកូនទាហានខ្លាតថយក្រោយប្រហែល ២០ ម៉ែត្រ ។ សូរកាំភ្លើងស្ងប់បន្តិច . . . កុសលខ្លួចរអើតមើលអាស្នាក៏ពុំឃើញដោយពាំងមើលគុម្ពោតព្រៃ . . . ។ គេមានការព្រួយបារម្ភខ្លាំងចំពោះជីវិតអាស្នា

... គេងាកមកបញ្ហាអាហារឱ្យឡើងម្តងទៀត ... តែឥតប្រយោជន៍ ... ខ្មាំងស្អប់យ៉ាងខ្លាំង ... ។ ដោយផ្ទះអាវុធខុសកន្លែងណាត់ និងខុសកាលកំណត់ធ្វើឲ្យកងទ័ពវៀតណាមរកភ្ជាប់សភាពការណ៍ពុំបាន ក៏យឺតយ៉ាវក្នុងការឡើងជួយ ... ។

ស្នូរកាំភ្លើងរប៉េះរប៉ោះមួយៗ ... អាស្នារដោយឈាមខ្មាំងពេញកងជីតមុខម្តងៗ លុះដឹងខ្លួនឡើងគេឃើញខ្មាំងកំពុងឆ្ពោះមករកគេៗ ក៏លើកកាំភ្លើងបាញ់ខ្មាំងភ្លាម ... ធ្វើឲ្យពួកវាពីរនាក់ដួលបះជើងប្រកាច់ស្លាប់មួយរំពេច ...! ពួកខ្មាំងក្តៅចិត្តរត់សម្រុកមករកអាស្នាទាំងម៉ូរម៉ោ អាស្នាបង្អើបកាំភ្លើងមើលនៅសល់គ្រាប់ ៣ គ្រាប់គត់ ក្នុងចិត្តគេបានសម្រេចថា "អាពីរនាក់នោះគឺសងឈាមប្រជាជនអាគ្រាប់នេះគឺសងឈាមឪពុកអញ" គេកេះកៃភ្លាំង ! ... ខ្មាំងមួយក្បាលដួលដូចប្រាថ្នា...! "គ្រាប់ទីពីរអញសងឈាមប្អូនស្រីអញ !»! ភ្លាំង !...

ខ្មាំងមួយក្បាលទៀតដួលប្រកាច់ក្នុងថ្លុកឈាមមួយរំពេច ! ... នៅសល់មួយគ្រាប់នេះ ! អាស្នាគិតរាវែក តើត្រូវគិតយ៉ាងណា អាស្នាដួលស្កាប់មុខ គិតបណ្តើរ "តើត្រូវបាញ់សម្លាប់ខ្លួនឯងឬយ៉ាងណា ! ... ទេៗ! ... ពាក្យចាស់លោកថា "សម្លាប់ខ្លួនឯងព្រះមិនប្រោសទេ" ទេ ! ខ្ញុំត្រូវតែបាញ់ខ្មាំង ... គ្រាប់មួយគ្រាប់នេះមានតម្លៃណាស់ !... ក្នុងពេលនេះ ... ខ្ញុំត្រូវតែដាច់ខាត ! ... មុននឹងខ្ញុំស្លាប់ ... ទុកឲ្យគ្រាប់របស់ខ្មាំងសម្លាប់ខ្ញុំវិញចុះ !...” ។



គិតសព្វគ្រប់ហើយ ... អាស្នាងើបក្បាលលួចមើលខ្មាំង រួចចាំបែរគោលកុងទោរកសត្រូវ ... គាប់ជួនពេលនោះខ្មាំងពីរនាក់បង្ហាញខ្លួនតែក្បាល គុម្ពោតព្រៃជិតនោះ អាស្នាដូចជាសង្ស័យមើលមិនច្បាស់ ក៏លើកដៃជូតភ្នែកដែលស្រវាំងរួចពិនិត្យមើលម្តងទៀត ... ប្រាកដណាស់ ក្នុងចំណោមពីរនាក់នោះ អាម្នាក់គឺអាម៉ោ។ ... អាស្នាស្គាល់ច្បាស់ កំហឹងឈឺចាប់ពុះពោរភ្លាមមួយរំពេច ... គេនឹកឃើញដល់ស្នាមរបួសរបស់គេ និងការសងឈាមដើម្បីចិន្ត្រាប្អូនប្រុសគេៗ ឈឺចាប់ណាស់... ដៃគេលូករកកាំភ្លើងទាំងរញ៉េរញ៉ៃ ហើយបួងសួងថា « បើពិតៈជាៈម្តាយខ្ញុំថ្លៃមែនសូមគុណព្រះអង្គជួយស្រោចស្រង់ជីវិតខ្ញុំព្រះអង្គផង ... ហើយសុំជួយដឹកនាំ... គ្រាប់កាំភ្លើងចុងក្រោយនេះ ទៅផ្តាច់ជីវិតអាម៉ោដែលជាឃាតករលើរូបប្អូនប្រុសខ្ញុំនិងពិសេសលើប្រជាជនកម្ពុជាឲ្យបានដាច់ខាត » ។

ផុតពីមាត់ស្មើរពុំទាន់ អាស្នាបានបង្ហើរគ្រាប់កាំភ្លើងចុងក្រោយនេះចំកណ្តាលដើមទ្រូងអាម៉ោដូចបំណង ...

ឃើញសត្រូវដួលភ្លាម ... អាស្នាសប្បាយចិត្តណាស់ ក៏ដួលបាត់មាត់រហូតទៅ ... ។

ស្នូរកាំភ្លើងផ្ទុះដូចលាចជាលើកទី ២ ជុំវិញសបញ្ជាក់ឲ្យដឹងថា ... កងទ័ពវៀតណាមឡើងមកជួយហើយ យល់ភាពអាសន្ន ខ្មាំងដកថយមួយរំពេចដោយបន្សល់ទុកខ្មោចគ្មាររលើសមរភូមិប្រយុទ្ធ ១២ នាក់ ... យល់សភាពការណ៍ហុចឲ្យ កុសលខំម៉្មថាទៅរកអាស្នាភ្លាម ទៅដល់...

អាស្នាបាត់មាត់ទៅហើយ . . . គេខំហៅអាស្នា: "អាស្នា ៗ សម្លាញ់យ៉ាងម៉េចទៅហើយ !"

ដោយស្តាប់ពីពចរនៅ កុសលក៏ចាក់ថ្នាំឃាត់ឈាមឲ្យនិងថ្នាំកម្លាំង ហើយសែងចេញមកក្រៅ ដែលមានពេទ្យកងទ័ពវៀតណាមជួយកំដររហូតឡើងរថយន្តទៅមន្ទីរពេទ្យសៀមរាប . . . ។

- យ៉ាងម៉េចទៅហើយលោកគ្រូពេទ្យ ? ( កុសលសួរ ) ។

- អូ ! . . . បាទ ! អ្នករបួសដឹងខ្លួនហើយ . . . តែ . . . មិនទាន់មានកម្លាំង ។

- តើរបួសនោះធ្ងន់ ឬ ស្រាល ? លោកគ្រូពេទ្យ . . .

គ្រូពេទ្យគិតបន្តិចក៏ឆ្លើយ :

- មិនជាធ្ងន់ធ្ងរប៉ុន្មានទេ ! មិត្ត ! . . តែអ្នករបួសចេះតែសួររកឈ្មោះភីនី តើភីនីនោះត្រូវជាយ៉ាងម៉េចនឹងអ្នករបួស ? ហើយឥឡូវនៅឯណា ?

- សួររកភីនី ! . . ( កុសលបញ្ជាក់ ) ភីនី ! . ត្រូវជាក្មួយកំព្រារបស់អ្នករបួស ហើយសព្វថ្ងៃនៅមណ្ឌលកុមារកំព្រាឯណោះ ! . . តើលោកគ្រូពេទ្យអនុញ្ញាតឲ្យជួបបានទេ ?

គ្រូពេទ្យគិតបន្តិចទើបឆ្លើយ :

- បាទ ! . . បាន ! . ហៅមកចុះ ! .

កុសលក៏ទៅតាមភីនីឲ្យមកជួបអាស្នា ! . .



មកដល់ភ្លាម ភីនីយំស្រែកបោកខ្លួនដូចអក ព្រោះពេលមកដល់អាស្នាត្រូវសន្លប់បាត់ស្មារតីធ្វើឲ្យភីនីនិងកុសលភ័យស្ទើរលោះព្រលឹង ។

- សុំអត់ទោស ! . សូមបងប្រុសនិងក្មួយស្រី អញ្ជើញចេញទៅក្រៅសិនចុះ . . . ចាំបីម៉ោងទៀតចាំខ្ញុំឲ្យដំណឹង ព្រោះអ្នករបួសនេះត្រូវធ្វើការវះកាត់ទើបបាន . . . ។

ភីនី យំពុំឈប់សោះ រៀបរាប់រឿងសព្វគ្រប់ធ្វើឲ្យកុសលទប់ទឹកភ្នែកពុំបាន នឹបភីនីយំទាំងអស់គ្នា . . . ។

- ភីនី ! . . . ក្មួយ ! . . . ពូនឹងប្រាប់ការពិតដល់ក្មួយ ! . . .

កាលដើមឡើយ ម្តាយក្មួយនិងអាស្នាត្រូវជាសង្សារស្ងាប់រស់ចិត្តមួយថ្លើមមួយជាមួយគ្នា ហើយរឿងនេះគឺជាមិត្តជិតស្និទ្ធបំផុតរបស់អាស្នារៀងរាវយ៉ាងណាក៏ពូដឹងដែរ . . . ក្រោយមកនៅឆ្នាំ ១៩៧៥ ពុលពតធ្វើរដ្ឋប្រហារ ... ក៏ជម្លៀសចេញទៅបែកគ្នាជាមួយអាស្នា ឯពូត្រូវនៅជួបជុំជាមួយម្តាយក្មួយ . . . ម្តាយក្មួយចិត្តល្អណាស់ហើយរូបសម្រស់ក៏ស្អាតទៀត ! . . . ថ្ងៃមួយនោះជីតាជីដូនក្មួយក៏ស្លាប់ចោលម្តាយក្មួយអស់ . . . ជីវិតម្តាយក្មួយនៅតែលតោល ដូនពេលនោះគេក៏ចាប់ម្តាយក្មួយឯង និងពូទៅដាក់សន្តិសុខ ។ នៅក្នុងមន្ទីរឃុំឃាំងម្តាយក្មួយត្រូវទទួលទារុណកម្មយ៉ាងព្រៃផ្សៃបំផុត ។

និយាយដល់ត្រង់នេះ កុសលចង់និយាយការពិតអំពីឪពុករបស់នាងឲ្យនាងដឹង ប៉ុន្តែគេហាក់ដូចជាស្ទាក់ស្ទើរ . . . គេឈប់ស្ងៀមមួយ

សន្ទុះ ភ្នែកគេសម្លឹងទៅឆ្ងាយហាក់ដូចជាកំពុងពិចារណាអំពីបញ្ហាអ្វីមួយ ។ គេគិតថាគេត្រូវតែលាក់រឿងនេះឲ្យជិត ។ គេលេបទឹកមាត់រួចបន្តទៀត...

ក្រោយមកគេបានដោះលែងពូ និងម្ដាយក្មួយពីមន្ទីរឃុំឃាំង ហើយពូក៏បែកពីម្ដាយក្មួយរហូតមក ។ ពូមិនបានដឹងថានរណាជាឪពុកក្មួយទេ ។

ពូគ្រាន់តែដឹងថាម្ដាយក្មួយដែលឡប់សតិនោះ ដោយសារតែពួកប៉ុលពតវាធ្វើបាបប៉ុណ្ណោះ ។ នៅឆ្នាំ ១៩៧៩ កងទ័ពរណសិរ្សបានមករំដោះ អាស្នាក៏រើសបានក្មួយយកទៅចិញ្ចឹម . . . ។ ក្នុងពេលអាស្នាធ្វើទាហានផ្លាស់ទៅនៅជីក្រែង អាស្នាបានជួបម្ដាយក្មួយ ឃើញម្ដាយក្មួយឆ្កួត អាស្នាខំយកទៅព្យាបាលតែឥតប្រយោជន៍ . . . ម្ដាយក្មួយក៏ចងកស្លាប់ទៅ . . . អាស្នាតែងលាក់រឿងនេះមិនដែលនិយាយប្រាប់ក្មួយទេ . . . ខ្លាចក្មួយរៀនពុំកើតណា ! . . ។

កុសលនិយាយលួងលោមភីនីបន្តទៀត :

- ភីនីក្មួយ ! សូមក្មួយ កុំព្រួយកុំកើតទុក្ខពេក របួសអាស្នាមិនធ្ងន់ទេ អាស្នាគង់តែជាសះស្បើយក្នុងពេលឆាប់ៗ នេះគេស្រឡាញ់ក្មួយដូចកូនគេបង្កើត ហើយគេរឹតតែស្រឡាញ់ និងអាណិតក្មួយថែមទៀតពេលបានដឹងថាក្មួយជាកូនរបស់សុទ្ធីនោះ ។ ក្មួយដឹងទេថា អាស្នានិងម្ដាយក្មួយគឺជាបងប្អូនជីដូនមួយណា. អាស្នាមានដែលនិយាយប្រាប់ក្មួយទេ ?

- អត់ទេពូ ! ... អញ្ចឹងពូអាស្នាត្រូវជាអ៊ំខ្ញុំមែនឬពូ ? (ភីនីចញ្ចាក់ដោយក្ដីត្រេកអរ ) ។



- ត្រូវហើយក្មួយ ព្រោះពូស្គាល់អាស្នានិងសុទ្ធីនេះតាំងពីនៅរៀនជាមួយគ្នាណាក្មួយ ។

- ខ្ញុំអរណាស់ពូ ! . . . ខ្ញុំបានអ៊ំនឹងគេហើយ ខ្ញុំឈប់ព្រួយហើយ . . . តែខ្ញុំ . . . ខ្ញុំភ័យនឹងរបួសគាត់ (ភីនីយំសោកអាណិតនិងភ័យចំពោះអាស្នាដែលពុំទាន់ដឹងជាយ៉ាងណា) ។

- ឈប់យំទៅក្មួយ អាស្នាពិតជាមិនស្លាប់ទេ ។ យើងបានជួបជុំគ្នាហើយ យើងលែងបែកគ្នាទៀតហើយ ក្មួយគិតតែពីខំរៀនទៅ បើមានការខ្វះខាតចាំពូជួយទំនុកបម្រុងថែមណាក្មួយ . . . ។

បន្ទាប់ពីពេលនោះបន្តិចក៏លេចឪពុកម្ដាយកុសល និងសុធានៅដល់ . . . សុធាយំ ឡើងហើមភ្នែក . . .

- ពុក ! ម៉ែ ! និងអូនសុធា មកពីអង្កាល់ ?

- ហ៊ឹ ! ពុកឮថាអាស្នាត្រូវរបួសភ្លាម ក៏ប្រញាប់មកតាំងពីម្សិល តែឡានខូចក៏ដេកផ្លូវមួយយប់ ។ ម៉ែឯថាមិនឯមកទេ នៅចាំផ្ទះ តែសុធាចេះច្រាស់ច្រាល់គេហ៊ក៏យកតាមវាមក ! . . . ចុះយ៉ាងម៉េចហើយកូន របួសអាស្នាមានសង្ឃឹមទេកូន ?

- បាទម៉ែ ! . . . លោកគ្រូពេទ្យបានប្រាប់ថា រង់ចាំបីម៉ោងទៀតចាំឲ្យជួប ព្រោះត្រូវធ្វើការវះកាត់ផង . . .

- ចុះក្មេងស្រីនេះត្រូវជាយ៉ាងម៉េចជាមួយអាស្នា ?

- បាទម៉ែ ! ត្រូវជាក្មួយ ! . . .

- អូ ! ហ្នឹងហើយ ឬដែលអាស្នាតែងនិយាយប្រាប់ថាកូយស្រី ។ កុមារកំព្រានោះ ?

- ហ្នឹងហើយម៉ែ !...

- សូមអញ្ជើញជួបអ្នករបួសចុះ ! ... អាចជួបបានហើយ...

- បាទ ! អរគុណ !...

ទាំងអស់គ្នាក៏ប្រញាប់ចូលទៅ ...

សុធាក្រឡេកឃើញអាស្នាភ្លាមស្ទុតចិត្តទប់មិនបានក៏យំខ្សឹកខ្សួល

- យ៉ាងម៉េចហើយអាស្នាកូយ ?

- បាទ ! ប្រហែលអត់អីទេ កម្លាំងក៏ហែងមានធម្មតាវិញហើយ ! ស្នាងាកមើលសុធាយ៉ាងញឹក) ។

កុសលយល់ចិត្តក៏ប្រាប់សុធា :

- សុធា ! ចូលទៅជិតអាស្នាទៅ !

សុធាអេះអុញ តែកុសលបង្ខំ ក៏ចូលទៅជិត ...

- បងអាស្នា ! យ៉ាងម៉េចទៅហើយ !

- អត់អីទេ ខ្ញុំអាចដាឆ្ងូចដើមបានក្នុងរយៈពេលដ៏ខ្លីខាងមុខនេះ ! គ្រូពេទ្យទៅដល់ ក៏ពោលដោយញញឹមថា ...

- ក្នុងរយៈពេលបីខែទៀតគាត់ជាសះស្បើយហើយកុំព្រួយ !

- ខ្ញុំអរគុណហើយលោកគ្រូពេទ្យ ដែលបានជួយជីវិតមិត្តខ្ញុំឲ្យរស់

## កែពាក្យខុសត្រូវ

| ល.រ | ទំព័រ | បន្ទាត់ | ពាក្យខុស | ពាក្យត្រូវ |
|---|---|---|---|---|
| 1 | ទំព័រមុខ | 12 | ទឹង | និង |
| 2 | 6 | 15 | អណោចអាធឬ | អាណោចអាធ័ម |
| 3 | 13 | 15 | អែអុក | អែរអុក |
| 4 | 19 | 12 | ផ្កាប់ ួប | ផ្កាប់រួម |
| 5 | 32 | 12 | ឆ្កួត | ឆ្គួត |
| 6 | 60 | 14 | ទុកទៅ | ទុកទៅ |
| 7 | 64 | 10 | បា | ផា |
| 8 | 55 | 12 | អាស្នាពាល | អាស្នាពោល |
| 9 | 74 | 6 | វា ួល | វាចូល |